**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៤ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

## ១- សេចក្តីផ្តើម

១-មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាល រួមមាន **ដំណាក់កាលទី១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ខែឧសភា, **ដំណាក់កាលទី២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ ផ្អែកលើក្របខណ្ឌគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ ដើម្បីឱ្យគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននីមួយៗ ពន្យល់និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងបង្ហាញអំពីតម្រូវការចំណាយរយៈពេល៣ ឆ្នាំ សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ។ នៅដំណាក់កាលទី ២ នេះ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៩ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដូច្នេះ សារាចរណែនាំនេះបានដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។ ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះជាពិសេសគោលការណ៍

នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយ ទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

២-សម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧,០% ប្រកបដោយបរិយាប័ន្ន និងសមធម៌ ហើយថែមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីឋានៈប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីចាត់ទុកថាជា "ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី" ក្នុងឆ្នាំ២០១៦។ កំណើនគួរឱ្យស្ញប់ស្ញែងនេះ បានបង្កើតការងារដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារពិភពលោកដែលបានបង្ហាញថា ភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាស្ថិតក្នុងអត្រា ០,៣% និងភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ ២០១៧។ ទន្ទឹមនេះ ប្រាក់ចំណូលប្រជាជនក៏មានការកើនឡើងផងដែរ ដោយ ផ.ស.ស. ក្នុងមនុស្សម្នាក់ កើនពី ១ ០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១ ៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង ១ ៥៦៣ ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។ ក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ លទ្ធផលប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយត្រូវបានស្ថាប័នអន្តរជាតិនានាវាយតម្លៃថា ជាសមិទ្ធផលមួយដែលមិនធ្លាប់មានពីមុនមក ក្នុងបណ្ដាប្រទេសក្នុងតំបន់ និងបណ្ដាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែល។ ចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់ ១៩,៦៤% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៧ ពោលគឺកើនឡើងជិត ២ ដង ឬប្រមាណ ៤,៥៨ ពិន្ទុភាគរយនៃ ផ.ស.ស.។ ទន្ទឹមនេះ ថវិកាចំណាយបានកើនប្រមាណ ១,៨ ដង ហើយការវិភាជថវិកាត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និង កម្រិតប្រតិបត្តិការ។

៣-ក្នុងបរិការណ៍ សេដ្ឋកិច្ចពិភពលោក និងតំបន់មានភាពប្រសើរឡើងដែលផ្តល់នូវបច្ច័យជាវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាជារួម ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅប្រឈមនឹងហានិភ័យមួយចំនួនផងដែរ រួមមាន៖ ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៃប្រទេសអភិវឌ្ឍន៍, ការឡើងថ្លៃប្រេង, ភាពមិនប្រាកដប្រជានៃផលប៉ះពាល់ពីការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប, ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក, កំណើនឆាប់រហ័សនៃឥណទានក្នុងប្រទេសចិន, ការបន្តនិន្នាការនៃគោលនយោបាយគាំពារនិយម និងបញ្ហាដែលពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ, ភេរវកម្ម និងសន្តិសុខជាសកល។ ទន្ទឹមនេះ កម្ពុជាក៏ជួបនូវបញ្ហាប្រឈម និងហានិភ័យក្នុងស្រុកមួយចំនួន រួមមាន៖ (១)-ថ្លៃអគ្គិសនីដែលនៅមានកម្រិតខ្ពស់ និងការផ្គត់ផ្គង់នៅមិនទាន់មានស្ថិរភាពល្អ; (២)-ភាពនៅទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក; (៣)-ផលិតភាពពលកម្មទាប និងកង្វះពលកម្មជំនាញ, នីតិវិធីស្មុគស្មាញ និងកម្រៃសេវាក្រៅផ្លូវការខ្ពស់សម្រាប់ការធ្វើធុរកិច្ច; (៤)-កម្រិតខ្ពស់នៃថ្លៃម្ហូបអាហារ; និង (៥)-កំណើនឆាប់រហ័សនៃឥណទានធនាគារក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ។

៤-យ៉ាងណាមិញ ឆ្នាំ២០១៩ ដែលជាឆ្នាំចាប់ផ្ដើមនៃរាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ទាមទារឱ្យរាជរដ្ឋាភិបាលមានការប្ដេជ្ញាចិត្តកាន់តែមោះមុតបន្ថែមទៀត ក្នុងការដោះស្រាយបញ្ហាប្រឈមរ៉ាំរ៉ៃដែលសេសសល់ ដើម្បីបង្កើនភាពប្រកួតប្រជែង, ធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការពង្រឹងក្បាលម៉ាស៊ីនកំណើនដែលមានស្រាប់ និងការស្វែងរកចន្លូលសេដ្ឋកិច្ចថ្មីដែលមានសក្ដានុពលខ្ពស់ ព្រមទាំងការរៀបចំខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដូចខាងក្រោម៖

## ២- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩

### ២.១- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៩

៥-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៧ កន្លងមកនេះ នៅបន្តរក្សាភាពរឹងមាំក្នុងអត្រាកំណើន ៧,០% ជាមួយនឹងអតិផរណាមធ្យមប្រចាំឆ្នាំក្នុងអត្រា ២,៩% និងអត្រាប្ដូរប្រាក់មធ្យមប្រមាណ ៤ ០៤៥ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់ ១ ៤២៧ ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាត្រូវបានចាត់ទុកថា សម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៦-នៅក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ហើយ ផ.ស.ស. តាមថ្លៃចរន្តឆ្នាំ២០១៨ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ៩៩ ៣៣២ ប៊ីលានរៀល និង ផ.ស.ស. តាមថ្លៃចរន្តឆ្នាំ២០១៩ ត្រូវបានគ្រោងចំនួន ១០៩ ៨៩៥ ប៊ីលានរៀល។ កំណើននេះបានមកពី៖

- វិស័យកសិកម្មនឹងបន្តសម្រេចបានកំណើនយឺតក្នុងរង្វង់ ១,៨% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ២,២% ក្នុងឆ្នាំទាំងពីរ ដោយកត្តាអាកាសធាតុអំណោយផល, ភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការកើនឡើងនៃថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ។ ម្យ៉ាងទៀត កម្រិតខ្ពស់នៃថ្លៃកៅស៊ូលើទីផ្សារអន្តរជាតិគួបផ្សំនឹងកំណើនខ្ពស់នៃផ្ទៃដីចៀរជ័រកៅស៊ូ នឹងលើកទឹកចិត្តឱ្យកសិករខ្នាតតូច និងក្រុមហ៊ុនឯកជនបង្កើនផលិតកម្មកៅស៊ូសម្រាប់ការនាំចេញ។ អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនល្អប្រសើរផងដែរ ដោយសារការបន្តកំណើនខ្ពស់នៃវារីវប្បកម្មនៅពេលដែលមាននិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ ការចិញ្ចឹមសត្វក៏ត្រូវបានព្យាករថានឹងមានកំណើនល្អ ដោយសារការបន្តកំណើននៃការចិញ្ចឹមគោ និងមាន់ធម្មជាតិបែបពាណិជ្ជកម្ម និងកំណើនផលិតកម្មជ្រូកដោយសារតែការងើបឡើងវិញនៃថ្លៃជ្រូករស់។ *ទោះបីជាយ៉ាងនេះក្ដីវិស័យកសិកម្មនៅបន្តជួបបញ្ហាប្រឈមជាច្រើន ដូចជា កំណើនផលិតភាពទាប កង្វះការវិនិយោគលើការកែច្នៃកសិផល, ពាណិជ្ជូបនីយកម្មកសិកម្ម និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។*

- វិស័យឧស្សាហកម្ម ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងអត្រា ១០,០% នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យសំណង់និងការបន្តកំណើននៃវិស័យកាត់ដេរ ស្របនឹងសន្ទុះ

កំណើនខ្ពស់នៃវិស័យកម្មន្តសាលមិនមែនកាត់ដេរទាំងសម្រាប់នាំចេញ និងបម្រើទីផ្សារក្នុងស្រុក។ វិស័យកាត់ដេរនៅរក្សាបានកំណើនក្នុងរង្វង់ ៥,០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដោយសារស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាមានភាពប្រសើរជាងការរំពឹងទុក។ ការរីកចម្រើននៃវិស័យសំណង់ ជាមួយនឹងអត្រាកំណើនប្រមាណ ១៦,៧% ក្នុងឆ្នាំ២០១៨ និង ១៦,៩% ក្នុងឆ្នាំ២០១៩ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការបន្តងាកទៅរកប្រភេទគម្រោងសំណង់ថ្លៃទាប និងមធ្យម ដែលជួយប៉ះប៉ូវដល់កំណើនយឺតនៃប្រភេទសំណង់ថ្លៃខ្ពស់។ ភាពរឹងមាំនៃវិស័យនេះត្រូវបានបន្តគាំទ្រ ដោយការអនុវត្តគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានតម្លៃសមរម្យ, ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងភាពជឿជាក់ចំពោះការវិនិយោគ ដោយសារភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចកម្ពុជា ទោះជាមានឥរិយាបទប្រុងប្រយ័ត្នពីសំណាក់វិនិយោគិនមួយចំនួនក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោតក៏ដោយ។ វិស័យឧស្សាហកម្មផ្សេងទៀតត្រូវបានរំពឹងថានៅរក្សាបាននូវកំណើនល្អដដែលក្នុងរង្វង់ ១១,៩ % ក្នុងឆ្នាំ២០១៨ និង ១២,២% ក្នុងឆ្នាំ២០១៩ ដោយសារការពង្រីកការវិនិយោគដែលមានស្រាប់ និងការវិនិយោគថ្មី ក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរដែលជាចន្ទល់កំណើនមួយដ៏រឹងមាំ រួមមានៈ ការផលិតម្ហូបអាហារនិងភេសជ្ជៈ គ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងបន្លាស់ គ្រឿងសង្ហារិម កង់ និង ស៊ីម៉ង់ត៍ជាដើម។

- វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ ក្នុងរង្វង់ប្រមាណ ៧,០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃកំណើនល្អប្រសើរនៃវិស័យទេសចរណ៍, លក់ដុំ-រាយ, អចលនទ្រព្យ និងវិស័យដឹកជញ្ជូន និងទូរគមនាគមន៍។ កំណើននៃវិស័យទេសចរណ៍ ត្រូវបានរំពឹងថាបន្តងើបឡើងក្នុងអត្រាកំណើន ៤,៥% ក្នុងឆ្នាំ២០១៨ និង ៤,៧% ក្នុងឆ្នាំ២០១៩ ដោយសារកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសភ្ញៀវទេសចរពីតំបន់អាស៊ី, ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ, ការលើកទឹកចិត្តឱ្យមានការបើកជើងហោះហើរត្រង់ និងការដាក់ចេញនូវគោលនយោបាយនានា ក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរបន្ថែម។ ***ទោះយ៉ាងនេះក្តី ការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍ ព្រមទាំងការទាក់ទាញភ្ញៀវចំណាយខ្ពស់ នៅតែជាប្រការចាំបាច់ និងបន្ទាន់ សំដៅធានាចីរភាពកំណើននៃវិស័យនេះដើម្បីបន្តតួនាទីជាចន្ទល់សំខាន់មួយសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។*** វិស័យអចលនទ្រព្យត្រូវបានរំពឹងថានឹងនៅតែមានកំណើនរឹងមាំក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលមាននិន្នាការស្របគ្នាទៅនឹងវិស័យសំណង់។ កំណើននេះនឹងត្រូវទ្រទ្រង់ដោយការកើនឡើងនៃសកម្មភាពទិញ-លក់សំណង់ អគារពាណិជ្ជកម្ម និងលំនៅស្ថានដែលមានថ្លៃទាបនិងមធ្យម ដែលប៉ះប៉ូវដល់ការថមថយនៃប្រតិបត្តិការទិញ-លក់ និងជួលលំនៅស្ថានថ្លៃខ្ពស់ ដោយសារកំណើនខ្លាំងនៃការផ្គត់ផ្គង់ធៀបនឹងតម្រូវការ។ វិស័យដឹកជញ្ជូន និងទូរគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តកំណើនក្នុងអត្រា ៧,៣% ក្នុងឆ្នាំ២០១៨ និង ៧,៥% ក្នុងឆ្នាំ២០១៩។ កំណើននៃវិស័យនេះនឹងត្រូវបានជំរុញដោយ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗដូចជាៈ ការបើកផ្លូវរថភ្លើងថ្មី (ភ្នំពេញ-ប៉ោយប៉ែត), ការពង្រីកព្រលានយន្តហោះ និងកំពង់ផែនានា និង ការធ្វើឱ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទីក ដែលនឹងជួយប៉ះប៉ូវដល់កំណើនយឺតនៃការនាំចេញផលិតផលកាត់ដេរ។ សម្រាប់ផ្នែកទូរគមនាគមន៍ផែនការវិនិយោគថ្មីលើបច្ចេកវិទ្យា5G និងការពង្រីកវិសាលភាពគ្របដណ្តប់ដល់តំបន់ដាច់ស្រយាលនឹងជួយជំរុញទីផ្សារអ៊ីនធឺណិតឱ្យមានសន្ទុះខ្លាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។

ទន្ទឹមគ្នានេះដែរ វិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងមានកំណើនរឹងមាំក្នុងអត្រា ៧,២% ក្នុងឆ្នាំ២០១៨ និង ៧,៣% ក្នុងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃការបន្តការកើនឡើងនូវការប្រើប្រាស់ក្នុងស្រុក។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់ក្នុងស្រុកត្រូវបានវាយតម្លៃថាមានសន្ទុះខ្លាំង ហើយនិន្នាការនេះនឹងនៅតែបន្ត ដោយសារកំណើនប្រជាជនដែលមានចំណូលមធ្យម (Middle Class) និងការផ្លាស់ប្តូរឥរិយាបថនៃការចាយវាយ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនហាងលក់ដុំ-រាយ និងបណ្តាភោជនីយដ្ឋាន និងហាងភេសជ្ជៈអន្តរជាតិជាច្រើន។ លើសពីនេះ ការបង្កើនចំណាយរបស់រាជរដ្ឋាភិបាលលើបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើនសមត្ថភាពចំណាយក្នុងស្រុកផងដែរ។

- អតិផរណាត្រូវបានប៉ាន់ស្មានថានឹងបន្តស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ស្របនឹងការរំពឹងទុកនៃកំណើនយឺតនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងកំណើនយឺតជាងមុននៃថ្លៃម្ហូបអាហារ។ អត្រាអតិផរណាជាមធ្យមនៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៣,៤% និង ៣,១% រៀងគ្នា។ អត្រាប្តូរប្រាក់ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានអត្រាជាមធ្យមគឺ ៤ ០៣៧ រៀលក្នុងមួយដុល្លារអាមេរិកនៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ខាងមុខ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

- ឱនភាពគណនីចរន្តត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៧,៤% និង ៧,២% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៨ និង ២០១៩ រៀងគ្នា។ ភាពប្រសើរឡើងនៃគណនីចរន្តនេះ នឹងឆ្លុះបញ្ចាំងតាមរយៈភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម, ការកើនឡើងខ្ពស់នៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងកំណើននៃប្រាក់បង្វែរឯកជនពីបរទេស (Remittances)។ ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ៩ ៤៩៤ លានដុល្លារអាមេរិក និង ១១ ០៥៩ លានដុល្លារអាមេរិកដែលធានាការនាំចូលបាន ៦,២ ខែ និង ៦,៥ ខែ រៀងគ្នា។

៧-ជារួម ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព, ស្ថិរភាពតម្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅកំណើន ផ.ស.ស. ឱ្យសម្រេចបានប្រមាណ ៧,០% សម្រាប់ឆ្នាំ២០១៨ និង ប្រមាណ ៧,១% សម្រាប់ឆ្នាំ២០១៩។ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាជាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ ៣,៥% ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយខិតខំជំរុញលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងរយៈពេលមធ្យម និង រយៈពេលវែង។

## ២.២- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៩

៨-ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ២០១៩ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូចបានគូសបញ្ជាក់ខាងលើ ព្រមជាមួយនឹងគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) មានគោលបំណងដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;

- ធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;

- បន្តធានាសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន ចីរភាព និងធន់នឹងវិបត្តិ ព្រមទាំងធានាបានស្ថិរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាអាចគ្រប់គ្រងបាន និងអត្រាប្តូរប្រាក់មានស្ថិរភាព;

- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;

- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥;

- បន្តគិតគូរ និងដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្របជូនដល់មន្ត្រីរាជការទូទៅ និងផ្តល់អាទិភាពលើការដំឡើងប្រាក់បំណាច់មុខងារជូនដល់មន្ត្រីក្នុងកម្រិតគ្រប់គ្រង និងមន្ត្រីដែលមានជំនាញខ្ពស់ ក្នុងក្របខណ្ឌនៃការផ្សារភ្ជាប់ការកែទម្រង់រដ្ឋបាលសាធារណៈទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ;

- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលជា "យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី" តាមរយៈការជំរុញវិនិយោគសាធារណៈឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈចាំបាច់សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម;

- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ, និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយ-ផលិតភាពឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច;

- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ, សម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល;

- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្តោតសំខាន់លើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, វិស័យថាមពល និងវិស័យឌីជីថល;

- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម;

- ពង្រឹងលំហថវិកា និងយន្តការគ្រប់គ្រងហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុ;

- ធានាអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាព សំដៅធានារក្សានូវចីរភាពបំណុល; និង

- បន្តពង្រឹងស្ថាប័នជាតិ និងអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និង តម្លាភាពនៃសេវាសាធារណៈ។

៩-ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៩ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ២០១៩ ដូចខាងក្រោម៖

## ២.២.១- ក្របខណ្ឌចំណូលថវិកាឆ្នាំ២០១៩

១០-គម្រោងចំណូលថវិកាឆ្នាំ២០១៩ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ២០១៩ គ្រោងសម្រេចឱ្យបាន ១៩,៤០% នៃ ផ.ស.ស. គឺមានកំណើន ០,៦៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៧% ធៀបនឹងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៨) ក្នុងនោះ៖

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ១៩,២២% នៃផ.ស.ស. គឺមានកំណើន ០,៦៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។ **ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៨,២៧% នៃផ.ស.ស. គឺថយចុះ ០,១២ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៩,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៧,០៨% នៃផ.ស.ស. គឺមានកំណើន ០,២៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៦៤% នៃផ.ស.ស. គឺមានកំណើន ០,២០ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៩,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។
- **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន០,១៨% នៃផ.ស.ស. គឺមានកំណើន ៧,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។
- ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៨៤%នៃផ.ស.ស. គឺមានកំណើន ០,២៦ ពិន្ទុភាគរយ នៃផ.ស.ស. ឬកើនឡើង ១៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,២៣% នៃ ផ.ស.ស.។

១១-ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្ដោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តប្រឹងប្រែងខ្លាំងក្លាជាងមុន ក្នុងការលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការកែសម្រួល និងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធដល់អ្នកបង់ពន្ធដើម្បីលើកកម្ពស់អនុលោមភាព, បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឬសគល់ និងការពង្រឹងការកៀរគរបន្ថែមនូវចំណូលមិនមែនសារពើពន្ធតាមបណ្ដាក្រសួង-ស្ថាប័ននានា។

### ក.១- ផ្នែកចំណូលពន្ធដារ

១២-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៩ រួមមាន៖

- ការបន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមានការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និង បណ្តឹងតវ៉ា តាមរយៈ៖

  - ការបន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលបានរកឃើញដោយការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;
  - ការលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក E-registration;
  - ការបន្តផ្តល់សេវាជូនអ្នកជាប់ពន្ធធំ មធ្យម និងតូច តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ;
  - ការបន្តចេញវិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពពន្ធ (Tax Compliance Award Certificate) ចំពោះអ្នកជាប់ពន្ធដែលមានអនុលោមភាពពន្ធខ្ពស់;
  - ការពង្រឹងការពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center) និងការជជែកផ្ទាល់ជាមួយពន្ធដារ (Live Chat) និងបញ្ជរនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ;
  - ការរៀបចំសៀវភៅណែនាំស្តីពីគោលការណ៍នៃកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា;
  - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment);
  - ការរៀបចំបញ្ជរទទួលលិខិតប្រកាសពន្ធដោយស្វ័យប្រវត្តិ (Automatic Tax Return Kiosk) តាមគោលដៅអ្នកជាប់ពន្ធសំខាន់ៗ;
  - ការបន្តពង្រឹងការវិភាគហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ ដោយកំណត់វិស័យដែលមានកម្រិតហានិភ័យខ្ពស់ ដូចជា វិស័យនាំចេញ-នាំចូល, វិស័យទេសចរណ៍, វិស័យសំណង់, វិស័យដឹកជញ្ជូន និងវិស័យដែលមានសក្តានុពលផ្សេងទៀតដល់កំណើនសេដ្ឋកិច្ច ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព;
  - ការបន្តជ្រើសរើសសហគ្រាសដែលមានបុគ្គលសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃ រវាងសហគ្រាស;
  - ការជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
  - ការបន្តបង្កើនការពិនិត្យផ្ទៀងផ្ទាត់ និងការប្រមូលទិន្នន័យផ្តុំព័ត៌មាន រួមមានការផ្ទៀងផ្ទាត់វិក្កយបត្រ អាករលើតម្លៃបន្ថែមនិងប្រភេទពន្ធផ្សេងៗ ដើម្បីកសាងកម្មវិធីសវនកម្ម និងការកំណត់ពន្ធឡើងវិញ; និង
  - អនុវត្តវិធានការពាក់ព័ន្ធដែលនឹងត្រូវបានដាក់ចេញនៅក្នុងក្របខណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។

- បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ៖

- ដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សរយៈពេល ០៥ ឆ្នាំ (២០១៩-២០២៣) និង ផែនការប្រតិបត្តិធនធានមនុស្សឆ្នាំ២០១៩;
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយអភិវឌ្ឍកម្មវិធីគ្រប់គ្រងការប្រមូលពន្ធតាមបច្ចេកវិទ្យាព័ត៌មាន;
- បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច-សង្គម រួមមាន៖ រៀបចំកែសម្រួលតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រា ផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងតម្លៃជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, រៀបចំកែសម្រួលប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា, រៀបចំប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៩ និងសិក្សាភាពខ្វះចន្លោះនៃច្បាប់ស្តីពីសារពើពន្ធ; និង
- រៀបចំបង្កើតវិធីសាស្ត្រតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារថ្នាក់ជាតិ, ក្នុងតំបន់ និងសកលលោក។

**ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ**

១៣-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០១៩ រួមមាន៖

- បន្តពង្រឹងរដ្ឋបាលគយតាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ,ការងារបច្ចេកទេសគយ, ការអនុវត្តច្បាប់លើទំនិញនាំចូលល្មើសកម្មសិទ្ធិបញ្ញា, ការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ, និងកិច្ចសហប្រតិបត្តិការអន្តរជាតិ រួមមាន ៖

- ពង្រឹងយន្តការគ្រប់គ្រងការអនុវត្តនីតិវិធីគយ តាមរយៈ៖ (១)-ការកត់ត្រានិងជម្រះបញ្ជីទំនិញនាំចូល, កិច្ចសហការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរកំពង់ផែ ដើម្បីកំណត់មុខសញ្ញាហានិភ័យមុនពេលទំនិញមកដល់, (២)-ការពង្រឹងបន្ថែមលើការគ្រប់គ្រងអាជីវកម្មលក់ទំនិញរួចពន្ធស្របតាមឧត្តមានុវត្តជាអន្តរជាតិ និង (៣)-ការដាក់ចេញនូវវិធានការដាក់លាក់ក្នុងការទារបំណុលពន្ធ និងអាករ;
- បង្កើនប្រសិទ្ធភាពលើការងារតម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើតតាមរយៈ៖ (១)-ការពិនិត្យឡើងវិញនូវការធ្វើមជ្ឈការនិងវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយទៅអង្គភាពគយ និងរដ្ឋាករមូលដ្ឋានឱ្យកាន់តែសមស្របតាមការវិវត្តសភាពការណ៍, (២)-ការកែសម្រួលនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត, (៣)-ការកែលម្អប្រព័ន្ធទិន្នន័យ គ្រប់គ្រងតាមមធ្យោបាយអេឡិចត្រូនិក, និង (៤)-ការតាមដាន និងវាយតម្លៃអនុលោមភាពការងារទាំងនេះឱ្យបានខ្ជាប់ខ្ជួន;
- កសាងនីតិវិធី, យន្តការចាំបាច់ និងបទប្បញ្ញត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បី៖ (១)-បង្កើនប្រសិទ្ធភាពការងារបង្ក្រាបការជួញដូរទំនិញល្មើសកម្មសិទ្ធិបញ្ញា, (២)-អភិវឌ្ឍប្រព័ន្ធកត់ត្រាការចុះបញ្ជីទំនិញដែលជាកម្មវត្ថុការពារកម្មសិទ្ធិបញ្ញា, និង (៣)-បង្កើតយន្តការផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋបាលគយជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយម្ចាស់កម្មសិទ្ធិ;

- ពង្រឹងប្រសិទ្ធភាពយន្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសទាំងនៅដើមទី កណ្តាលទី និងចុងទី តាមរយៈការងារស្រាវជ្រាវ, ស៊ើបអង្កេត, ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទ ទាំងបទល្មើសឆ្លងដែន, ចរាចរណ៍សាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុខុសច្បាប់ និងការនាំចូលពុំស្របច្បាប់ និង/ឬ ហាមឃាត់ផ្សេងទៀត;
- បង្កើនកិច្ចសហប្រតិបត្តិការ, ការធ្វើសមាហរណកម្ម និងសុខដុមនីយកម្មកិច្ចការគយ ទាំងក្នុងកម្រិតតំបន់ និងសកលលោកដើម្បី៖ (១)-ធានាប្រសិទ្ធភាពនៃការផ្លាស់ប្តូរព័ត៌មានស្ថិតិពាណិជ្ជកម្ម, (២)-បង្ការ និងបង្ក្រាបបទល្មើសឆ្លងកាត់ព្រំដែន និងបទល្មើសគេចពន្ធ, (៣)-ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការអនុវត្តពន្ធអនុគ្រោះនៃកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីក្នុងក្របខណ្ឌអាស៊ាន និងអាស៊ានជាមួយដៃគូ, និង (៤)- ចែករំលែកចំណេះដឹងបទពិសោធន៍; និង
- អនុវត្តវិធានការពាក់ព័ន្ធនឹងផ្នែកពន្ធគយ ដែលនឹងត្រូវដាក់ចេញនៅក្នុងក្របខណ្ឌកែទម្រង់ប្រព័ន្ធពន្ធ ឆ្នាំ២០១៩-២០២៣។

- ការបន្តការពង្រឹងយន្តការគាំទ្រ តាមរយៈ៖
  - ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការអនុវត្តយន្តការប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត, ការវាយតម្លៃធុរជន, ការពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងហានិភ័យ, ការកែសម្រួលសមាសភាព និងការពង្រីកភាពគ្របដណ្តប់នៃប្រតិបត្តិការសវនកម្មគយ ក្រោយពេលបញ្ចេញទំនិញ, និងការផ្លាស់ប្តូរព័ត៌មានទាំងផ្ទៃក្នុងអង្គភាពគយ និងជាមួយស្ថាប័នពាក់ព័ន្ធ;
  - ពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាត្រួតពិនិត្យក្នុងការងារគយ តាមរយៈ៖ (១)-ការបន្តពង្រីកវិសាលភាពគ្របដណ្តប់នៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា), (២)-ការកែលម្អ និងបន្ថែមមុខងារគាំទ្រនីតិវិធីគយផ្សេងៗដល់ប្រព័ន្ធ, និង (៣)-ការតភ្ជាប់រវាងប្រព័ន្ធអាស៊ីគូដាជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត;
  - បន្តរៀបចំអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិសម្រាប់ "ដំណាក់កាលទី២" គឺគ្រោងតភ្ជាប់ទៅស្ថាប័នពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតក្នុងទម្រង់អេឡិចត្រូនិកប្រើប្រាស់សម្រាប់ការបញ្ចេញទំនិញពីគយ បន្ទាប់ពីការចូលរួមបញ្ចូន និងទទួលវិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញក្នុងទម្រង់អេឡិចត្រូនិក (e-FORM D)។ ក្នុងដំណាក់កាលទី២នេះ ក្រសួង-ស្ថាប័នដែលអាចតភ្ជាប់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ រួមមាន៖ ក្រសួងសុខាភិបាល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំបន់សេដ្ឋកិច្ចពិសេស, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល;
  - ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់ម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ តាមរយៈការបង្កើតមជ្ឈមណ្ឌលទទួលរូបភាពម៉ាស៊ីនស្កេន និងយន្តការគាំទ្រចាំបាច់ផ្សេងទៀត;

○ ជំរុញវិសាលភាពនៃការអនុវត្តនីតិវិធីឆ្លងកាត់គយ តាមរយៈការចូលរួមក្នុងសមាសភាពក្រុមការងារថ្នាក់ជាតិ និងយន្តការគាំទ្រចាំបាច់នានា; និង
○ ពង្រឹងអភិបាលកិច្ចអង្គភាពគយ និងអភិវឌ្ឍន៍ស្ថាប័ន តាមរយៈការបណ្តុះបណ្តាល និងកែលម្អយន្តការវាយតម្លៃ, យន្តការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់មន្ត្រីគយ និងបុគ្គលពាក់ព័ន្ធ។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៤-វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ២០១៩ រួមមាន៖

- បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការតាមដាន, ការកត់ត្រា និងការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;

- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេលជាមួយយន្តការដែលមានស្រាប់;

- បន្តពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាព, តម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវ, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ចតាមរយៈការអនុវត្តបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជាធរមាន;

- បន្តជំរុញ និងលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីសម្រេចបានការធ្វើទំនើបកម្មនៃការកត់ត្រា, ការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និងទាន់ពេលវេលា;

- បន្តជំរុញការគ្រប់គ្រងសាច់ប្រាក់របស់ក្រសួង-ស្ថាប័ន តាមរយៈប្រព័ន្ធធនាគារក្នុងការបង់ចំណូលចូលថវិកាជាតិ។ ក្រសួង-ស្ថាប័នត្រូវសិក្សាបន្ថែមលើសេវាប្រកួតប្រជែងរបស់បណ្តាធនាគារដៃគូដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការបង់ចំណូល;

- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូលឱ្យមានភាពងាយស្រួល និងតម្លាភាព;

- ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យប្រេង-ឧស្ម័ន ដើម្បីការកៀរគរចំណូលពីវិស័យនេះ;

- ពង្រឹង និងពន្លឿនការអនុវត្តយន្តការដែលបានព្រមព្រៀង និងឯកភាពរួមមាន៖ កម្រៃអាកាសចរស៊ីវិល (CAF), ការបង់កម្រៃលេខទូរគមនាគមន៍, ការបង់កម្រៃពីហ្វ្រេកង់ ព្រមទាំងពន្លឿនការងាររៀបចំកែប្រែកម្រៃអាជ្ញាប័ណ្ណឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ;

- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដោយសហការជាមួយបណ្តាស្ថាប័ននានា;

- បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍របស់រាជរដ្ឋាភិបាល;

- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមការកាន់កាប់របស់ក្រសួង-ស្ថាប័នសាមី ជាពិសេសការធ្វើបច្ចុប្បន្នភាពកិច្ចសន្យា, កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្បទាននានា ឱ្យសមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត;

- ស្នើគ្រប់ក្រសួង-ស្ថាប័នបន្តកិច្ចសហការល្អ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការផ្តល់ទិន្នន័យ, កិច្ចព្រមព្រៀង, កិច្ចសន្យា និងឯកសារពាក់ព័ន្ធនានា ដើម្បីបន្តពង្រឹងយន្តការប្រមូលចំណូលឱ្យអស់លទ្ធភាព និងប្រកបដោយប្រសិទ្ធភាព;

- ស្នើអាជ្ញាធរសវនកម្មជាតិពង្រឹងការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;

- ពង្រឹង និងពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត ដើម្បីកៀរគរចំណូលឱ្យអស់លទ្ធភាព;

- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់; និង

- អនុវត្តវិធានការផ្សេងទៀត ពាក់ព័ន្ធនឹងផ្នែកចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបានដាក់ចេញនៅក្នុងឯកសារយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣។

### ២.២.២- ក្របខណ្ឌចំណាយថវិកាឆ្នាំ២០១៩

១៥-គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានកំណត់ និងវិភាជ ដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋ** សម្រាប់ឆ្នាំ២០១៩ ត្រូវបានគ្រោងស្មើនឹង ២៤,៤៧% នៃផ.ស.ស. គឺថយចុះ ០,០៧ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ១០,៣% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៨)។ ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ**នឹងកម្រិតត្រឹម ១៥,៩៧% នៃផ.ស.ស. គឺថយចុះ ០,០៨ ពិន្ទុភាគរយ នៃផ.ស.ស. ប៉ុន្តែមានកំណើន ១០,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ ដែលគម្រោងចំណាយបន្ទុកបុគ្គលិក មានប្រមាណ ៤៧,៤% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើប្រមាណ ៧,៥៦% នៃផ.ស.ស. ដោយផ្តល់អាទិភាពទៅលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ។ *គួរគូសបញ្ជាក់ផងដែរថា តួលេខសមាមាត្រនៃចំណាយបន្ទុកបុគ្គលិកមានការថយចុះ ធៀបឆ្នាំ២០១៨ ដោយសារថវិកាចំណាយសម្រាប់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបានផ្លាស់ប្តូរការកត់ត្រាពីក្នុងប្រភេទចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ទៅកត់ត្រាជាចំណាយអត្ថប្រយោជន៍សង្គម (ជំពូក ៦២) ក្នុងប្រភេទចំណាយក្រៅបន្ទុកបុគ្គលិកវិញដើម្បីឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ។* **ចំណាយមូលធន** ត្រូវបានគ្រោងស្មើនឹង ៨,៥០% នៃផ.ស.ស. គឺមានកំណើន ០,០១ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១០,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ២,៨៣% នៃផ.ស.ស. គឺថយចុះ ០,៣៤ ពិន្ទុភាគរយនៃផ.ស.ស. ឬថយចុះ ១,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ និង**ចំណាយសម្រាប់ការទូទាត់ប្រាក់ខ្ចី** ត្រូវបានគ្រោងក្នុងកម្រិត ០,៨២% នៃផ.ស.ស. កើនឡើង ២២,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។ ទន្ទឹមនេះ **ចំណាយមូលធនដោយ**

**ហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ៤,៨៤% នៃផ.ស.ស. គឺមានកំណើន ០,២៦ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។

- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ លើមូលដ្ឋាននៃការបន្តខិតខំបង្កើនប្រសិទ្ធភាពចំណាយ (ទាំងប្រសិទ្ធភាពក្នុងការវិភាជ, ទាំងប្រសិទ្ធភាពក្នុងផ្នែកប្រតិបត្តិការ) ដូចខាងក្រោម៖

- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត ៥,៧៤% នៃផ.ស.ស. គឺមានកំណើន ០,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១.៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨,
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត១,៣០% នៃផ.ស.ស. គឺថយចុះ ០,០៩ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៣,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨,
- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងក្នុងកម្រិត ១,៩៦% នៃផ.ស.ស. គឺថយចុះ ០,៣២ ពិន្ទុភាគរយនៃផ.ស.ស. ឬថយចុះ ៤,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ ដោយថវិកា គ.ជ.ប នឹងថយចុះក្រោយឆ្នាំបោះឆ្នោត,
- **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងក្នុងកម្រិត ៣,៩៣% នៃផ.ស.ស. គឺមានកំណើន ០,០១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១០,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨។

- **ចំណាយចរន្តថវិការាជធានី ខេត្ត, មូលនិធិក្រុង ស្រុក ខណ្ឌ និង មូលនិធិឃុំ-សង្កាត់** ត្រូវកំណត់ត្រឹម ១,៧០% នៃផ.ស.ស. កើនឡើង ២៧,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ ដែលក្នុងនោះ ថវិកាផ្ទាល់របស់រាជធានី-ខេត្ត សរុបមានប្រមាណ ០,៩៧% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី-ខេត្ត ស្មើនឹង ០,០៨% នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិ ក្រុង ស្រុក ខណ្ឌ ស្មើនឹង ០,១៧% នៃ ផ.ស.ស. ឬស្មើនឹង១,១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ២០១៨, និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៩ ស្មើនឹង ០,៤៨% នៃផ.ស.ស. ឬស្មើនឹង ៣,០០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៨។

១៦-ក្នុងក្របខណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តយុទ្ធសាស្ត្រ និង ក្របខណ្ឌនៃ***វិធានការដើម្បីបង្កើនប្រសិទ្ធភាពចំណាយ*** ដូចខាងក្រោម៖

- បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃ៖ (១)-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, (២)-ការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់ជាក់ស្តែង និង ចំទិសដៅ, និង (៣)-ការអនុវត្តថវិកា;

- ពង្រឹងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័ន ទាំងនៅរដ្ឋបាលកណ្តាល មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងពង្រីកការសាកល្បងបន្ថែមទៀតនៅថ្នាក់ក្រោមជាតិ;

- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌,

សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;

- បន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី;

- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីក, និងកសិកម្ម;

- បន្តគាំទ្រការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥;

- បន្តគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន;

- បន្តការរឹតត្បិតចំណាយមិនចាំបាច់ ដើម្បីជំរុញការអនុវត្តគោលនយោបាយសំខាន់ៗ និងកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល;

- ធានាប្រសិទ្ធភាពនៃការវិភាជ និងប្រើប្រាស់ថវិកាសម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត;

- បន្តបង្កើនការវិនិយោគសាធារណៈដើម្បីជំរុញការធ្វើពិពិធកម្ម, ការបង្កើនផលិតភាព និងភាពប្រកួតប្រជែងក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព តាមរយៈការធ្វើវិចារណកម្ម គោលនយោបាយចំណាយ;

- បន្តជំរុញអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ, ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជននៅទីជនបទ;

- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយទាំងចំណាយចរន្ត និងចំណាយមូលធន;

- ពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្ត៖ (១)-ការកែសម្រួលនីតិវិធីចំណាយ, (២)-ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់, (៣)-ការពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (៤)-ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, (៥)-ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និង (៦)-ការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុនិងជំហានបន្ទាប់ផ្សេងៗទៀត;

- លើកកម្ពស់គុណភាពការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងអនុលោមភាពនៃការអនុវត្តផែនការនេះ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំឱ្យកាន់តែមានប្រសិទ្ធភាព និងធានាឱ្យការអនុវត្តថវិកាទាន់ពេលវេលាចាប់ពីដើមឆ្នាំ។ ក្នុងន័យនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់

ថវិកាចំណាយ ដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ជាបណ្ដើរៗចាប់ពីពេលរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់មក នៅក្នុងពេលលើកសំណើគម្រោងថវិកាឆ្នាំ២០១៩ ដែលនឹងត្រូវរៀបចំនៅក្នុងអំឡុងខែ មិថុនា និងខែ កក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នឹងតម្រូវឱ្យភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០១៩ របស់ខ្លួន សម្រាប់ការប្រជុំពិភាក្សា និងចរចាកញ្ចប់ថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្មត្រូវអនុលោមតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម។

- បន្តគិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ;

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្ដីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះដែលបានគ្រោង រួមមាន៖

  - ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈ៖ (១)-ការរៀបចំអនុក្រឹត្យស្ដីពីគោលការណ៍ណែនាំរួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (PIM), (២)-ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍, និង (៣)-ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP);
  - ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្រោមក្របខណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងទីផ្សារមូលបត្រ; និង

- ពង្រឹងការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាន និងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី៖ (១)-ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, (២)-វិស័យធនាគារ និងហិរញ្ញវត្ថុ, និង (៣)-ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ២.២.៣-ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ២០១៩

១៧-ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និង ផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ៣,២៥% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,០៧% នៃផ.ស.ស. នៅក្នុងឆ្នាំ២០១៩។ ប្រការនេះ នឹងផ្ដល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែង

របស់សេដ្ឋកិច្ចកម្ពុជា និងការបន្តដំឡើងបៀវត្សសមរម្យជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ទន្ទឹមនឹងការបន្តជានារក្សាបាននូវលំហថវិកាក្នុងទំហំមួយសមស្របសម្រាប់ត្រៀមទប់ទល់នឹងវិបត្តិ ក៏ដូចជាហានិភ័យនានាដែលអាចកើតមានឡើងដោយថាហេតុ។

## ៣- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៩

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ២០១៩

១៨-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ២០១៨),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ២០១៩

១៩-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ដែលបាននិងកំពុង**អនុវត្តថវិកាកម្មវិធី** ត្រូវបន្ត និងយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព និង ជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អ រចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ និងស៊ីសង្វាក់គ្នាដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ ***សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។***

២០-គ្រប់ក្រសួង-ស្ថាប័ន **និងមន្ទីរជំនាញរាជធានី-ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់

ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និង ចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៧ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ២០១៨ និងដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២១-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ២០១៩-២០២១, ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ២០១៩ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី- ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួលនិងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតទៅតាមគោលការណ៍នៃការដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គឺចៀសវាងការគ្រោងបៀវត្ស ឬ បន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោលមិនប្រើប្រាស់ដូចឆ្នាំកន្លងមក។ គោលការណ៍សម្រាប់ការគ្រោងបន្ទុកបុគ្គលិកឆ្នាំ២០១៩ រួមមាន៖

- ត្រូវគ្រោង**ចំនួនក្របខណ្ឌថ្មី** យ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ និងត្រូវបញ្ជាក់ពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័ន អាចស្នើប្រើប្រាស់ថវិកានោះដើម្បី**ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់** និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ជាពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗរបស់ក្រសួង-ស្ថាប័ន,*
- ត្រូវគ្រោង**បៀវត្សមូលដ្ឋាន** ដោយផ្អែកតាមក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០១៨, តាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ ដោយ**ដំឡើងបៀវត្សមូលដ្ឋាន** តាមតម្លៃសន្ទស្សន៍ ២ ៣៤០ រៀល ដោយគិតចាប់ពីខែមករា ដល់ ខែធ្នូ គឺមានកំណើនស្មើនឹង ១០% ក្នុងមួយឆ្នាំ,
- ត្រូវគ្រោងដំឡើង**ប្រាក់បំណាច់មុខងារ**ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយផ្តល់បន្ថែមជូន ៣០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ក្នុងកម្រិតចាប់ពី ៧៥០ ០០០ រៀល ចុះក្រោម ដោយគិតចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៩,

- ត្រូវគ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យា មិនឱ្យលើសពីចំនួនដែលក្រសួងមុខងារសាធារណៈផ្តល់ជូនឆ្នាំ២០១៨ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងដំឡើងពី ៦០០ ០០០ រៀល ទៅដល់ ៦៥០ ០០០ រៀល ដោយគិតចាប់ពីខែមករា ដល់ ខែធ្នូ,
- **ដោយឡែកចំពោះការគ្រោងថវិកាមន្ត្រីមានជំងឺ (អនុគណនី ៦៤០៥១)** ដែលធ្លាប់ត្រូវបានគ្រោងនៅឆ្នាំកន្លងមក, គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **មិនចាំបាច់ត្រូវគ្រោងថវិកាសម្រាប់មុខសញ្ញានេះ សម្រាប់ឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់** ដោយសាររបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ និងត្រូវបានដាក់ឱ្យអនុវត្តដោយៈ (១)- អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និង(២)- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់ អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន,
- ចំពោះកញ្ចប់ថវិកាសម្រាប់ការដំឡើងរបបសន្តិសុខសង្គមអប្បបរមាប្រចាំខែ នឹងត្រូវបានគ្រោងដោយឡែកនៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដើម្បីបន្តកាត់បន្ថយគម្លាតប្រាក់សោធននិវត្តន៍រវាងអ្នកចូលនិវត្តចាស់ និងថ្មី ហើយការដំឡើងនេះនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ដោយគិតចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ ២០១៩។
- ជាមួយគ្នានេះ សម្រាប់ឆ្នាំ២០១៩ នេះ និងឆ្នាំបន្តបន្ទាប់ ការគ្រោងសម្រាប់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលធ្លាប់ត្រូវបានគ្រោងនៅតាមមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ត្រូវផ្ទេរមកគ្រោងថវិកាផ្ទាល់នៅក្រោមកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាវិញ តាមរយៈ **បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស) និង បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ)** ដែលជាអង្គភាពទទួលខុសត្រូវលើការគ្រប់គ្រង និងបើកផ្តល់។ ប្រាក់ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល ត្រូវគ្រោងនៅក្នុងអនុគណនី ៦២០១២,

ចំណែកប្រាក់ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ត្រូវគ្រោងនៅក្នុងអនុគណនី ៦២០១៣ ។

**ខ- ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន)** ជាសរុបសម្រាប់ឆ្នាំ២០១៩ ត្រូវគ្រោងក្នុងកម្រិតអតិបរមាត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ព្រោះអាទិភាពចំណាយឆ្នាំ២០១៩ ត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ "ថវិកាឆ្នាំ២០១៩ ត្រូវផ្តោតជាសំខាន់លើការដំឡើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ព្រមទាំងជាមួយគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation)"។*ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ ២០១៩ នឹងទទួលបានស្មើឆ្នាំ២០១៨ ដោយស្វ័យប្រវត្តិនោះដែរ* ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ហើយថវិកាដែលបានកាត់ចេញមិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញនោះទេ លុះត្រាតែផ្តល់ការពន្យល់យ៉ាងត្រឹមត្រូវ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ដែលមានសមិទ្ធិកម្មល្អលើការងារកែទម្រង់ដែលត្រូវបានទទួលស្គាល់ជាសាធារណៈនោះ នឹងទទួលបាននូវការលើកទឹកចិត្ត។ ដូច្នេះ *គ្រប់ក្រសួង-ស្ថាប័ន ត្រូវធ្វើអាទិភាវូបនីយកម្មនៃអាទិភាពគោលនយោបាយ និងថ្លឹងថ្លែងបែងចែកថវិការវាងកម្មវិធីនីមួយៗ ជាពិសេសកម្មវិធីស្នូលរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀត នៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាច ទៅតាមនិងរវាងអង្គភាពថវិកានីមួយៗក្នុងក្របខណ្ឌពិដានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី*។ ក្នុងន័យនេះដែរ ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវគ្រោងដោយឈរលើគោលការណ៍ ដូចខាងក្រោម៖

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូល ដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៧ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ២០១៨ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ២០១៨ ហើយលែងត្រូវការនៅក្នុងឆ្នាំ២០១៩ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៨។ ក្នុងន័យនេះ **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុជាយថាហេតុ** ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ និងមានយុត្តការណ៍អំពីភាពចាំបាច់និងបន្ទាន់ ដោយត្រូវពន្យល់និងផ្តល់អំណះអំណាងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវអំពីសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីទាំងនោះ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់។ **សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលបំពេញតាមលក្ខខណ្ឌចាំបាច់ដូចបានរៀបរាប់នេះ ទើបចាត់ទុកជាកម្មវត្ថុ នៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។**

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីពិដានកញ្ចប់ថវិកា ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

**គ.ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០១៩ របស់ខ្លួនចំនួនពីរច្បាប់ (មួយច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង មួយច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្មត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ១ ខែ ធ្នូ** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និង អនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

**ឃ. ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក២១)** ត្រូវអនុវត្តតាមក្របខណ្ឌនៃការវិភាជដោយឡែក ដោយអនុលោមតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ក្នុងការកំណត់អាទិភាពគម្រោង និងទំហំថវិកាសម្រាប់ឆ្នាំ ២០១៩ ដែលមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ២០១៨។ សម្រាប់ក្រសួង-ស្ថាប័នដែលត្រូវទទួលបានការវិភាជថវិកាជាទៀងទាត់ទំហំថវិកានឹងត្រូវបានវិភាជស្របតាមគោលនយោបាយ ស្របជាមួយនឹងដំណើរការនៃការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។ ចំពោះគម្រោងអាទិភាពលម្អិត គឺជាកម្មវត្ថុនៃកិច្ចពិភាក្សាក្រោមយន្តការអន្តរក្រសួងដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើង។ ដោយឡែកសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលជាកម្មវត្ថុទទួលបានថវិកាពីកញ្ចប់ឥណទានមិនទាន់បែងចែក ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្របដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាពភាវូបនីយកម្មគម្រោងស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ទៅតាមលទ្ធភាពថវិកា។

ទន្ទឹមនេះ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សាត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវតែជាគម្រោងដែលមានក្នុងក្របខណ្ឌគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង-ស្ថាប័នសាមី,
- ជាគម្រោងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់,
- ជាគម្រោងដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម,
- ចំពោះគម្រោងធំៗ ត្រូវមានការសិក្សាសមិទ្ធិច្បាស់លាស់។

២២-ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៨ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់យ៉ាងច្រើនត្រឹមកម្រិតឆ្នាំ២០១៨។ ប៉ុន្តែ ការរៀបចំគម្រោងចំណាយលម្អិតតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងវិភាជថវិកា ព្រោះ ***ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពឥណទានថវិកាផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២*** *ហើយត្រូវផ្អែកលើហេតុផល និងលទ្ធផលការងារដែលសម្រេចបាន។*

២៣-ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើការ**គណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ ជំពូក៦៣ និង ជំពូក៦៥ ដោយផ្អែកលើមូលដ្ឋានពីបន្ថែមទៀត ដូចខាងក្រោម៖

*- កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។* ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ទនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។**

*- កំណត់ចំណាយមិនប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយ ជារៀងរាល់ឆ្នាំរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និង បេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ។

២៤-ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុង** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។ ទំហំឥណទានដែលនៅសល់ក្នុងក្របខណ្ឌពិដាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុង**ក្រសួង-ស្ថាប័នដដែល ឬ ទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញនៃក្រសួងមួយ ទៅមន្ទីរជំនាញនៃក្រសួងមួយទៀតបាន** ក្នុងក្របខណ្ឌនៃវិស័យចំណាយតែមួយ។

២៥-ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៧ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និង

វាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬ ការកាត់បន្ថយគម្រោងចំណាយឆ្នាំ២០១៩ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ២០១៧ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០១៨ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០១៩។*

២៦-ទន្ទឹមនេះដែរ ត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៨ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ក្នុងការរៀបចំថវិកាឆ្នាំ២០១៩ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្ត មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

២៧-ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់-ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ៣.៣- ការវិវត្តនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៩

២៨-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សានិងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងធ្វើការបូកសរុបចំណូល-ចំណាយ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីនៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៨ ដើម្បីគណៈ-រដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨។**

២៩-ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៩ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ **ការចរចាថវិកាកម្រិតបច្ចេកទេស និង កម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និង អនុគណនី) និង/ឬ តាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)** លើមូលដ្ឋាននៃគោលការណ៍ និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីជានាប្រសិទ្ធភាពនៃការវិភាជថវិកាក្នុងកម្រិតនៃពិដានកញ្ចប់ថវិកាឆ្នាំ២០១៩ដែលបានកំណត់ និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្តនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៨ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការ-គ្រប់គ្រងឆ្នាំ២០១៩ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៤- សេចក្តីសន្និដ្ឋាន

៣០-ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធីដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង ប្រកបដោយចីរភាពក្នុងរង្វង់ ៧% និង កាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និងសុខុមាលភាពប្រជាជន។

៣១-ទោះជាយ៉ាងណាក្តី ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកាដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃ

ទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣២-ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ថ្ងៃ ពុធ ៥ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ